**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:១៣៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលមាត្រា ៤ និងមាត្រា ១៣ នៃអនុក្រឹត្យលេខ ១២១ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំង រក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការពារជាតិ
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ១៣ សសរ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលគណៈកម្មាធិការជាតិ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្ម រក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកែសម្រួល និងតម្លើងមជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ ១២១ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា មួយ.-**

ត្រូវបានកែសម្រួលមាត្រា ៤ និងមាត្រា ១៣ នៃអនុក្រឹត្យលេខ ១២១ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម ដូចតទៅ៖

**មាត្រា ៤ ថ្មី.-**

ម.ជ.រ.ប.ក មានរចនាសម្ព័ន្ធដូចខាងក្រោម:
- លេខាធិការដ្ឋាន
- ជំនាញគ្រប់គ្រង ធនធានមនុស្ស និងបណ្តុះបណ្តាល
- ជំនាញគ្រប់គ្រង ភស្តុភារ ហិរញ្ញវត្ថុ និងសុខាភិបាល

- ជំនាញគ្រប់គ្រង ស្តង់ដាសម្ភារៈ និងបច្ចេកទេស
- នាយកដ្ឋានស្រាវជ្រាវ ទិន្នន័យ និងវិស្វកម្ម
- នាយកដ្ឋានកាកសំណល់សង្គ្រាម គ្រឿងផ្ទុះ និងព័ត៌មាន
- នាយកដ្ឋានទំនាក់ទំនង សហប្រតិបត្តិការ រក្សាសន្តិភាព និងនីតិកម្ម
- វិទ្យាស្ថានហ្វឹកហ្វឺនបណ្តុះបណ្តាល កងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម
- សាលាហ្វឹកហ្វឺនកងកម្លាំងរក្សាសន្តិភាពពហុជាតិ ហៅកាត់ថា ស.ហ.ក.រ.ស.ព ជាភាសាអង់គ្លេសសរសេរថា Training School for Multinational Peace Keeping Operation ហៅកាត់ថា TSMPKO ។

អង្គការលេខ នៃ ម.ជ.រ.ប.ក ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា ១៣ ថ្មី.-**

វិទ្យាស្ថានហ្វឹកហ្វឺនបណ្តុះបណ្តាលកងកម្លាំង រក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម និងសាលាហ្វឹកហ្វឺនកងកម្លាំងរក្សាសន្តិភាពពហុជាតិ នៃមជ្ឈមណ្ឌលជាតិគ្រប់គ្រង កងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម មានភារកិច្ចដូចតទៅ៖

**ក/**-ភារកិច្ចរបស់វិទ្យាស្ថានហ្វឹកហ្វឺនបណ្តុះបណ្តាលកងកម្លាំង រក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម មានដូចខាងក្រោម៖

- រៀបចំផែនការ និងហ្វឹកហ្វឺនបណ្តុះបណ្តាលគ្រប់ជំនាញ ក្នុងរយៈពេលវែង មធ្យម ខ្លី ស្របតាមស្តង់ដាជាតិ អន្តរជាតិ
- សិក្សា ស្រាវជ្រាវ និងដកបទពិសោធន៍ នូវការអនុវត្តថ្មីៗ ដែលសមស្របតាមស្តង់ដា អង្គការសហប្រជាជាតិ
- ហ្វឹកហ្វឺនសិក្ខាកាមជាតិ និងអន្តរជាតិ ផ្នែករក្សាសន្តិភាព ផ្នែកបោសសំអាតមីន ផ្នែកកំទេចគ្រឿងផ្ទុះ ផ្នែកវិស្វកម្ម មានវិស្វករសំណង់បញ្ឈរ ផ្តេក ជម្រកសុវត្ថិភាព ផ្នែកភាសាបរទេស និងសង្គតការណ៍យោធា-ស៊ីវិល
- ធ្វើទស្សនកិច្ចសិក្សាស្វែងយល់ ទំនាក់ទំនង ដកស្រង់បទពិសោធន៍ ជាមួយបណ្តា វិទ្យាស្ថាន សាលាហ្វឹកហ្វឺន ស្ថាប័ន និងអង្គភាពនានា ក្នុង និងក្រៅប្រទេស
- វាយតម្លៃការសិក្សារបស់សិក្ខាកាមក្រោយបញ្ចប់វគ្គសិក្សានីមួយៗ ដើម្បីជ្រើសរើសសិក្ខាកាម ដែលមានពិន្ទុល្អៗ ធ្វើជាអ្នកផ្តល់បទពិសោធន៍ដល់សិក្ខាកាម ដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់
- សហការជាមួយក្រសួង ស្ថាប័ននានា បណ្តាប្រទេសជាដៃគូ និងអង្គការសហប្រជាជាតិ ស្វែងរកគ្រូយោធាចារ្យ មន្ត្រីជំនាញជាតិ-អន្តរជាតិ និងអង្គការសហប្រជាជាតិល្អៗ សម្រាប់មកហ្វឹកហ្វឺនបណ្តុះបណ្តាលដល់កងកម្លាំងពហុជាតិ
- ផ្តល់លិខិតបញ្ជាក់ការសិក្សាដល់សិក្ខាកាមជាតិ-អន្តរជាតិ ដែលបានបញ្ចប់ការសិក្សា
- បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឲ្យ។

វិទ្យាស្ថានហ្វឹកហ្វឺនបណ្តុះបណ្តាលកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម មានឋានៈស្មើនឹងនាយកដ្ឋាន និងដឹកនាំដោយនាយកមួយរូប អមដោយនាយករងបីរូប។

**ខ/**-ភារកិច្ចរបស់សាលាហ្វឹកហ្វឺនកងកម្លាំងរក្សាសន្តិភាពពហុជាតិ មានដូចខាងក្រោម៖

- រៀបចំផែនការ និងហ្វឹកហ្វឺនគ្រប់ជំនាញក្នុងរយៈពេលមធ្យម ខ្លី ស្របតាមស្តង់ដាជាតិ-អន្តរជាតិ
- សិក្សា ស្រាវជ្រាវ និងដកបទពិសោធន៍នូវការអនុវត្តថ្មីៗ ដែលសមស្របតាមស្តង់ដា អង្គការសហប្រជាជាតិ
- ហ្វឹកហ្វឺនដល់សិក្ខាកាមជាតិ និងអន្តរជាតិ ផ្នែករក្សាសន្តិភាព ផ្នែកត្រួតពិនិត្យការចល័ត ផ្នែកនគរបាលផ្នែកកងអាវុធហត្ថ ផ្នែកសុខាភិបាល ផ្នែកគាំទ្រកស្តុភារ នាយទាហានសេនាធិការ ផ្នែកប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ផ្នែកសង្គ្រោះគ្រោះមហន្តរាយ ផ្នែកគីមីសាស្ត្រ ផ្នែកភាសាបរទេស ផ្នែកការពារ និងចែកចាយស្បៀងដល់ជនភៀសខ្លួន សម្រាប់ចូលរួមបេសកកម្មរក្សាសន្តិភាព អង្គការសហប្រជាជាតិលើវិស័យមនុស្សធម៌
- ធ្វើទស្សនកិច្ចសិក្សាស្វែងយល់ ទំនាក់ទំនង សហការ និងដកស្រង់បទពិសោធន៍ ជាមួយបណ្តាវិទ្យាស្ថាន សាលាហ្វឹកហ្វឺន ស្ថាប័ន និងអង្គភាពនានា

- វាយតម្លៃការសិក្សារបស់សិក្ខាកាមក្រោយបញ្ចប់វគ្គសិក្សានីមួយៗ ដើម្បីជ្រើសរើសសិក្ខាកាម ដែលមានពិន្ទុល្អៗ ធ្វើជាអ្នកផ្តល់បទពិសោធន៍ដល់សិក្ខាកាម ដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់
- សហការជាមួយក្រសួង ស្ថាប័ននានា បណ្តាប្រទេសជាដៃគូ និងអង្គការសហប្រជាជាតិ ស្វែងរកគ្រូយោធាចារ្យ មន្ត្រីជំនាញជាតិ-អន្តរជាតិ និងអង្គការសហប្រជាជាតិល្អៗ សម្រាប់មកហ្វឹកហ្វឺនបណ្តុះបណ្តាលដល់កងកម្លាំងពហុជាតិ
- ទទួលភារកិច្ចធ្វើលំហាត់ហ្វឹកហ្វឺន ប្រតិបត្តិការរក្សាសន្តិភាពពហុជាតិ និងជាទីលានហ្វឹកហ្វឺនរបស់កងយោធពលខេមរភូមិន្ទ
- ផ្តល់លិខិតបញ្ជាក់ការសិក្សាដល់សិក្ខាកាមជាតិ-អន្តរជាតិ ដែលបានបញ្ចប់ការសិក្សា
- បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកប្រគល់ឲ្យ។

សាលាហ្វឹកហ្វឺនកងកម្លាំងរក្សាសន្តិភាពពហុជាតិមានឋានៈស្មើនឹងនាយកដ្ឋាន និងដឹកនាំដោយនាយកមួយរូប អមដោយនាយករងបីរូប។

**មាត្រា ពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា បី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្ម រក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា បី
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ